ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះវិហារ**

សំណុំរឿងរដ្ឋប្បវេណីលេខ:៥០

ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២

សាលក្រមរដ្ឋប្បវេណីលេខ: ៩ "ក"

ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តព្រះវិហារ

-បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២។

## ចៅក្រមជំនុំជម្រះ

-ឯកឧត្តម[redacted] ជាប្រធានសាលាដំបូងខេត្តព្រះវិហារ

## ក្រឡាបញ្ជីសវនាការ

-លោក[redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ

## ដើមចោទ

-ឈ្មោះ [redacted] ចាន់ណា ភេទប្រុស អាយុ៤៩ឆ្នាំ ជាតិខ្មែរ រស់នៅភូមិ[redacted] ដោយមានលោក[redacted] ជាមេធាវីតំណាងដោយអាណត្តិ។

## ចុងចម្លើយ

-ឈ្មោះ [redacted] ជីវ័ន្ត ភេទស្រី អាយុ៣៧ឆ្នាំ ជាតិខ្មែរ រស់នៅភូមិ[redacted]។

## អង្គហេតុ និងចំណុចវិវាទ

ក./ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារអោយតុលាការចេញ

-សុំលែងលះពីប្រពន្ធឈ្មោះ [redacted] ជីវ័ន្ត។

-សុំទាមទារបែងចែកទ្រព្យសម្បត្តិរួម។

-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

**ខ.ដំណើររឿងក្ដី និងចំណុចវិវាទ**

**ខ.១./ការសង្ខេបអំពីរឿងក្ដី**

ដើមចោទ និងចុងចម្លើយជាប្តីប្រពន្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ ដោយការរស់នៅជាមួយគ្នាមិនចុះសម្រុងឈ្លោះទាស់ទែងគ្នាជាញឹកញាប់ និងរស់នៅបែកលំនៅគ្នា ធ្វើអោយដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធ ហើយបានដាក់ពាក្យប្តឹងសុំលែងលះមកតុលាការ។

**ខ.២./អង្គហេតុដែលគ្មានវិវាទ**

ដើមចោទ និងចុងចម្លើយជាប្តីប្រពន្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ បានរស់នៅមិនចុះ

សំរុងគ្នាឈ្លោះទាស់ទែងគ្នា និងរស់នៅបែកលំនៅគ្នា។

**ខ.៣./ចំណុចវិវាទ**

តើការប្តឹងទាមទារលែងលះរបស់ដើមចោទមានមូលហេតុត្រឹមត្រូវដែរឬទេ?

ការសុំសិទ្ធិទ្រព្យសម្បត្តិមានលក្ខណៈត្រឹមត្រូវដែរឬទេ?

**ខ.៤./ការអះអាងរបស់ភាគី**

**ខ.៤.១./ការអះអាងរបស់ដើមចោទ**

កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ ខ្លួនគ្រាន់តែបានសែនព្រេនជាមួយឈ្មោះ [redacted] ជីវ័ន្ត ដោយមិនបានរៀបការតាមប្រពៃណីនោះទេ ហើយក៏បានរួមរស់នៅជាមួយគ្នា រហូតដល់ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ ឈ្មោះ [redacted] ជីវ័ន្ត បានបបួលខ្លួនទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ហើយខ្លួនក៏យល់ព្រមតាម ដោយមានចិត្តអាណិតគាត់ក៏ជាមេម៉ាយ ហើយខ្លួនក៏ជាពោះម៉ាយដូចគ្នា ដាក់ចិត្តដាក់កាយ សង្ឃឹមថាបានរួមនៅជាមួយគ្នាបានសុភមង្គល។

ប៉ុន្តែក្រោយពីបានចុះសំបុត្រអាពាហ៍ពិពាហ៍រួចមក ឈ្មោះ [redacted] ជីវ័ន្ត តែងតែរករឿងឈ្លោះជាមួយខ្លួនជាញឹកញាប់ដោយគ្មានមូលហេតុត្រឹមត្រូវណាមួយឡើយដែលធ្វើអោយខ្លួនពិបាកក្នុងការរួមនៅជាមួយគាត់។ ពេលខ្លះថែមទាំងប្រើហិង្សាមកលើខ្លួនទៀតផង ប៉ុន្តែខ្លួនមិនបានតបតទៅគាត់វិញទេ ជេរប្រមាថគ្រប់សព្វបែបយ៉ាងមើលងាយមកលើខ្លួន ដោយមិនចាត់ទុកខ្លួនជាប្តីរបស់គាត់ទេ ជេរខ្លួនដោយប្រើពាក្យពេជន៍អាក្រក់ៗ មកលើខ្លួន។ ម្យ៉ាងវិញទៀត ខ្លួន និងឈ្មោះ [redacted] ជីវ័ន្ត មានផ្ទះរស់នៅរៀងៗ ខ្លួន ពេលខ្លះ ក៏បានរួមនៅជាមួយគ្នា ហើយពេលខ្លះទៀត ក៏មិនបានរួមនៅជាមួយគ្នាទេ និងតាំងថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២២ ខ្លួន និងឈ្មោះ [redacted] ជីវ័ន្ត បានបែកលំនៅគ្នារហូតមកដល់បច្ចុប្បន្ននេះ។ ខ្លួននៅតែសូមធ្វើការទាមទារលែងលះពីចុងចម្លើយឈ្មោះ [redacted] ជីវ័ន្ត ដដែល។ ខ្លួន និងឈ្មោះ អម ជីវ័ន្ត មិនមានកូននោះទេ។

**ចំពោះទ្រព្យសម្បត្តិរួមមានដូចខាងក្រោម៖**

-ដីដែលមានទំហំ ០៥ ម៉ែត្រ គុណ ១៥ ម៉ែត្រ ស្មើនឹង ៧៥ ម៉ែត្រការ៉េ ដោយមានសង់ផ្ទះជាប្រភេទវីឡា និងទំហំផ្ទះ E0 ដែលមានទំហំ ០៥ ម៉ែត្រ គុណ ០៩ ម៉ែត្រ, E1 ដែលមានទំហំ ០៥ ម៉ែត្រ គុណ ១១,២០ ម៉ែត្រ ផ្ទះលេខ:B-97 នៃ សុខហេងវីឡា ដែលមានទីតាំងស្ថិតនៅភូមិគោកត្នោត ឃុំសណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

-ផ្ទះនៅកូនភ្នំសង់នៅលើដីរបស់ដើមចោទមានទំហំ ៦ ម៉ែត្រ គុណ ១៤,៧ ម៉ែត្រ ធ្វើអំពីឈើលើថ្មក្រោម មានទីតាំងស្ថិតនៅភូមិហ្សែត សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ។

ខ្លួនសូមប្រគល់ដីដែលមានទំហំ ០៥ ម៉ែត្រ គុណ ១៥ ម៉ែត្រ ស្មើនឹង ៧៥ ម៉ែត្រការ៉េ ដោយមានសង់ផ្ទះជាប្រភេទវីឡា និងទំហំផ្ទះ E0 ដែលមានទំហំ ០៥ ម៉ែត្រ គុណ ០៩ ម៉ែត្រ, E1 ដែលមានទំហំ ០៥ ម៉ែត្រ គុណ ១១,២០ ម៉ែត្រ ផ្ទះលេខ:B-97 នៃសុខហេងវីឡា ដែលមានទីតាំងស្ថិតនៅភូមិគោកត្នោត ឃុំសណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប អោយទៅឈ្មោះ [redacted] ជីវ័ន្ត ជាចុងចម្លើយ។



Scanned with CamScanner

ចំណែកឯផ្ទះនៅក្លូនភ្នំសង់នៅលើដីរបស់ខ្លួនមានទំហំ ៦ ម៉ែត្រ គុណ ១៤,៧ ម៉ែត្រ ធ្វើអំពីឈើលើថ្មក្រោម មានទីតាំងស្ថិតនៅភូមិហ្សែត សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ ខ្លួនសូមទាមទារយក និងសូមប្រគល់ប្រាក់ចំនួន ៥០០០ (ប្រាំពាន់) ដុល្លារ ទៅអោយចុងចម្លើយ។

អាស្រ័យហេតុនេះ ខ្លួនសូមអោយតុលាការមេត្តាចេញសាលក្រមតាមការទាមទាររបស់ខ្លួនដោយក្ដីអនុគ្រោះផង។

ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ខ្លួន។

**ខ.៤.២./ការអះអាងរបស់ចុងចម្លើយ**

ខ្លួនពិតជាបានសែនព្រេនកាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ ហើយចុះសំបុត្រអាពាហ៍ពិពាហ៍នៅថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០២២ នៅសាលាសង្កាត់កំពង់ប្រណាក។ ខ្លួនឯកភាពលើការទាមទារលែងលះរបស់ដើមចោទឈ្មោះ [redacted] ចាន់ណា។ ម្យ៉ាងទៀត ខ្លួន និងដើមចោទបែកលំនៅគ្នាតាំងពីពេលដែលដើមចោទបានដាក់ពាក្យបណ្ដឹងមកតុលាការ។ ចំណែកឯកូនវិញ ខ្លួន និងឈ្មោះ [redacted] ចាន់ណា មិនមានទេ។

អំពីទ្រព្យរួមមាន៖

-ផ្ទះនៅក្លូនភ្នំសង់នៅលើដីរបស់ដើមចោទមានទំហំ ៦ ម៉ែត្រ គុណ ១៤,៧ ម៉ែត្រ ធ្វើអំពីឈើលើថ្មក្រោម មានទីតាំងស្ថិតនៅភូមិហ្សែត សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ ខ្លួនឯកភាពសូមប្រគល់អោយទៅដើមចោទ ហើយខ្លួនឯកភាពទទួលយកប្រាក់ចំនួន ៥០០០ (ប្រាំពាន់) ដុល្លារ ពីដើមចោទ។

-ផ្ទះនៅសៀមរាបមានដីទំហំ ០៥ ម៉ែត្រ គុណ ១៥ ម៉ែត្រ ស្មើនឹង ៧៥ ម៉ែត្រការ៉េ ដោយមានសង់ផ្ទះជាប្រភេទវីឡា និងទំហំផ្ទះ E0 ដែលមានទំហំ ០៥ ម៉ែត្រ គុណ ០៩ ម៉ែត្រ, E1 ដែលមានទំហំ ០៥ ម៉ែត្រ គុណ ១១,២០ ម៉ែត្រ ផ្ទះលេខ:B-97 នៃសុខហេងវីឡា ដែលមានទីតាំងស្ថិតនៅភូមិគោកត្នោត ឃុំសណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ខ្លួនឯកភាពទទួលយក។

**គ./អំពីឯកសារភស្តុតាង**

-សំបុត្រអាពាហ៍ពិពាហ៍លេខ:០៨ចុះថ្ងៃទី០៧ខែមីនាឆ្នាំ២០២២របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់កំពង់ប្រណាក។

-កិច្ចសន្យាទិញលក់ចុះថ្ងៃទី១០ខែមករា ឆ្នាំ២០២០។

## សំអាងហេតុ

**ក./ អំពីការលែងលះ**

ដើមចោទនៅតែសុំលែងលះ ដោយលើកហេតុផល នៃភាពមិនចុះសម្រុងគ្នា ឈ្លោះប្រកែកគ្នាជាញឹកញាប់ ដោយការរស់នៅបែកលំនៅគ្នាតាំងពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២២។ ឯចុងចម្លើយក៏ឯកភាពយល់ព្រមលែងលះដែរ។

ដើមចោទ និងចុងចម្លើយជាប្ដីប្រពន្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

តុលាការកត់សម្គាល់ឃើញថា៖

-ដើមចោទ និងចុងចម្លើយរស់នៅមិនចុះសំរុងគ្នា ឈ្លោះប្រកែកគ្នាជាញឹកញាប់ ហើយបានរស់នៅបែក



Scanned with CamScanner

លំនៅគ្នាតាំងពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២២ ដែលផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍។

-អាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ហើយ គ្មានសង្ឃឹមថា អាចនឹងធ្វើបដិទានឡើងវិញបាន។

ដូច្នេះការសុំទាមទារលែងលះរបស់ដើមចោទមានមូលហេតុ ត្រឹមត្រូវតាមមាត្រា៩៧៨ ចំណុច "ឃ និង ង" នៃក្រមរដ្ឋប្បវេណី គប្បីតុលាការសម្រេចតាមការទាមទារនេះ។

**ខ./អំពីទ្រព្យសម្បត្តិរួម**

តាមការអះអាងរបស់ដើមចោទ និងចុងចម្លើយ ឃើញថាទ្រព្យសម្បត្តិរួមមាន៖

-ដីដែលមានទំហំ ០៥ ម៉ែត្រ គុណ ១៥ ម៉ែត្រ ស្មើនឹង ៧៥ ម៉ែត្រការ៉េ ដោយមានសង់ផ្ទះជាប្រភេទវីឡា និងទំហំផ្ទះ E0 ដែលមានទំហំ ០៥ ម៉ែត្រ គុណ ០៩ ម៉ែត្រ, E1 ដែលមានទំហំ ០៥ ម៉ែត្រ គុណ ១១,២០ ម៉ែត្រ ផ្ទះលេខ: B-97 នៃ សុខហេងវីឡា ដែលមានទីតាំងស្ថិតនៅភូមិគោកត្នោត ឃុំសណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

-ផ្ទះនៅកូនភ្នំសង់នៅលើដីរបស់ដើមចោទមានទំហំ ៦ ម៉ែត្រ គុណ ១៤,៧ ម៉ែត្រ ធ្វើអំពីឈើលើថ្មក្រោម មានទីតាំងស្ថិតនៅភូមិហ្សសែត សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ។

ដើមចោទយល់ព្រមប្រគល់ដីដែលមានទំហំ ០៥ ម៉ែត្រ គុណ ១៥ ម៉ែត្រ ស្មើនឹង ៧៥ ម៉ែត្រការ៉េ ដោយមានសង់ផ្ទះជាប្រភេទវីឡា និងទំហំផ្ទះ E0 ដែលមានទំហំ ០៥ ម៉ែត្រ គុណ ០៩ ម៉ែត្រ, E1 ដែលមានទំហំ ០៥ ម៉ែត្រ គុណ ១១,២០ ម៉ែត្រ ផ្ទះលេខ:B-97 នៃសុខហេងវីឡា ដែលមានទីតាំងស្ថិតនៅភូមិគោកត្នោត ឃុំសណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប អោយទៅចុងចម្លើយ។ ចុងចម្លើយក៏ឯកភាពទទួលយកដីផ្ទះនេះដែរតាមការទាមទាររបស់ដើមចោទ។

ចំណែកឯផ្ទះនៅកូនភ្នំសង់នៅលើដីរបស់ដើមចោទមានទំហំ ៦ ម៉ែត្រ គុណ ១៤,៧ ម៉ែត្រ ធ្វើអំពីឈើលើថ្មក្រោម មានទីតាំងស្ថិតនៅភូមិហ្សសែត សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ ដើមចោទយល់ព្រមទទួលយក និងសូមប្រគល់ប្រាក់ចំនួន ៥០០០ (ប្រាំពាន់) ដុល្លារ ទៅអោយចុងចម្លើយ។ ចុងចម្លើយក៏ឯកភាពប្រគល់ផ្ទះនេះទៅអោយដើមចោទ និងចុងចម្លើយយល់ព្រមទទួលយកនូវប្រាក់ចំនួន ៥០០០ (ប្រាំពាន់) ដុល្លារ ពីដើមចោទ។

ការពិភាក្សា និងឯកភាពគ្នារវាងដើមចោទ និងចុងចម្លើយដូចករណីខាងលើនេះ អំពីការបែងចែកទ្រព្យសម្បត្តិរួម មានលក្ខណៈត្រឹមត្រូវតាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី គប្បីតុលាការសម្រេចតាមការទាមទារនេះ។

ប្រាក់ប្រដាប់ក្ដី គប្បីជាបន្ទុករបស់ដើមចោទតាមការអះអាងរបស់សាមីភាគីដើមចោទ។

ក្នុងរឿងក្ដីរដ្ឋប្បវេណីនេះតុលាការធ្វើការសម្រេចសេចក្ដីដូចខាងក្រោម៖

**<u>សេចក្ដីសម្រេចបញ្ចប់</u>**

១./ឱ្យដើមចោទឈ្មោះ [redacted] ចាន់ណា លែងលះពីចុងចម្លើយឈ្មោះ [redacted] ជីវ័ន្ត ។

២./ភាគីចុងចម្លើយឈ្មោះ [redacted] ជីវ័ន្ត ត្រូវទទួលបានដីដែលមានទំហំ ០៥ ម៉ែត្រ គុណ ១៥ ម៉ែត្រ ស្មើនឹង ៧៥ ម៉ែត្រការ៉េ ដោយមានសង់ផ្ទះជាប្រភេទវីឡា និងទំហំផ្ទះ E0 ដែលមានទំហំ ០៥ ម៉ែត្រ គុណ ០៩ ម៉ែត្រ, E1 ដែលមានទំហំ ០៥ ម៉ែត្រ គុណ ១១,២០ ម៉ែត្រ ផ្ទះលេខ:B-97 នៃសុខហេងវីឡា ដែលមានទីតាំងស្ថិតនៅភូមិគោកត្នោត



Scanned with CamScanner

ឃុំសណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប និងភាគីដើមចោត្រូវទទួលបាននៅកូនភ្នំសង់នៅលើដីរបស់ដើមចោទមានទំហំ ៦ ម៉ែត្រ គុណ ១៤,៧ ម៉ែត្រ ធ្វើអំពីឈើលើថ្មក្រោម មានទីតាំងស្ថិតនៅភូមិហ្សសែត សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ ហើយភាគីដើមចោទឈ្មោះ [redacted] ចាន់ណា ត្រូវប្រគល់ប្រាក់ចំនួន ៥០០០ (ប្រាំពាន់) ដុល្លារ អោយទៅភាគីចុងចម្លើយឈ្មោះ [redacted] ជីវ័ន្ត ។

៣./ឱ្យចុងចម្លើយឈ្មោះ [redacted] ជីវ័ន្ត ស្ថិតក្នុងភាពជាមេម៉ាយរយៈពេលចំនួន ១២០ (មួយរយម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រមស្ពាព តទៅ។

៤./ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះបានប្រកាសនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២។ ក្នុងករណីដែលប្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងនៅក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ថ្ងៃបានទទួលលិខិតសាលក្រមនេះ។

ថ្ងៃពុធ ២កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ខេត្តព្រះវិហារ, ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ២កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តព្រះវិហារ, ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]